**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ២៥០ ក.ប/ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៣

# ប្រកាស
# ស្តីពី
# អធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន

-តាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១**.-

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំណត់ឲ្យមានអធិការកិច្ចទៅលើទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងបទបញ្ញានានាទាក់ទងដល់ការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស។

**ប្រការ២**.-

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចុះធ្វើអធិការកិច្ចសាមញ្ញដល់ទីកន្លែងនៃទីភ្នាក់ងារជ្រើសរើសឯកជនទាំងឡាយ រួមទាំងមជ្ឈមណ្ឌលណែនាំតម្រង់ទិសមុនចេញដំណើរស្របទៅតាមច្បាប់ និងបទបញ្ញានានា។

**ប្រការ៣**.-

ក្នុងករណីទទួលបានរបាយការណ៍ ឬពាក្យបណ្តឹងពាក់ព័ន្ធនឹងវិវាទការងារ លក្ខខណ្ឌការងារ ជំងឺ និងគ្រោះថ្នាក់ការងារ សិទ្ធិការងាររបស់ពលករ ឬការប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ និងបទបញ្ញានានា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចុះធ្វើអធិការកិច្ចពិសេសទៅលើទីភ្នាក់ងារជ្រើសរើសឯកជន និងមជ្ឈមណ្ឌលណែនាំតម្រង់ទិសមុនចេញដំណើរទៅតាមករណីនីមួយៗ។

ក្នុងករណីចាំបាច់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចស្នើសុំកិច្ចសហការពីស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

ក្នុងករណីរកឃើញមានបទល្មើសព្រហ្មទណ្ឌ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបញ្ជូនសំណុំរឿងទៅស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចចាត់ការតាមនីតិវិធីច្បាប់។

**ប្រការ៤**.-

មន្ត្រីដែលត្រូវចុះធ្វើអធិការកិច្ចលើទីភ្នាក់ងារជ្រើសរើសឯកជន មានសិទ្ធិពិនិត្យមើលក្នុងបរិវេណ ទីតាំង អគារ មជ្ឈមណ្ឌលណែនាំតម្រង់ទិសមុនចេញដំណើរ និងមានសិទ្ធិទាមទារឲ្យទីភ្នាក់ងារជ្រើសរើសឯកជនបង្ហាញឯកសារចាំបាច់នានា ដូចជា សៀវភៅបន្ទុកគ្រប់គ្រងពលករ កំណត់ត្រាបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារ បញ្ជីឈ្មោះបុគ្គលិក សៀវភៅបើកប្រាក់ឈ្នួលបុគ្គលិក កិច្ចសន្យាសេវារកការងារឲ្យធ្វើ និងកិច្ចសន្យាការងាររបស់ពលករ បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលណែនាំតម្រង់ទិសមុនចេញដំណើរ និងបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារជ្រើសរើសឯកជនជាដើម។

**ប្រការ៥.-**

រាល់ពេលចុះធ្វើអធិការកិច្ច ត្រូវមានកំណត់ហេតុបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការអនុវត្តត្រឹមត្រូវ ឬមិនត្រឹមត្រូវតាមច្បាប់ និងបទបញ្ញា ក៏ដូចជាការផ្តល់អនុសាសន៍នានាសម្រាប់ការអនុវត្ត។ កំណត់ហេតុនោះត្រូវចុះហត្ថលេខាដោយអធិការការងារមានសមត្ថកិច្ច និងតំណាងស្របច្បាប់នៃសាមីទីភ្នាក់ងារជ្រើសរើសឯកជន។

**ប្រការ៦.-**

ក្នុងករណីពិនិត្យឃើញថាមានកំហុស ដោយមិនបានអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ញានានា មន្ត្រីអធិការកិច្ចត្រូវពិនិត្យឲ្យបានច្បាស់លាស់ និងផ្តល់មូលវិចារណ៍ជូនថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការណែនាំព្រមានឬដកអាជ្ញាប័ណ្ណដើម្បីចាត់ការតាមនីតិវិធីស្របទៅតាមករណីនីមួយៗ។

ក្នុងករណីពិនិត្យឃើញថា ទីភ្នាក់ងារជ្រើសរើសឯកជនបានអនុវត្តផ្ទុយពីច្បាប់ និងបទបញ្ញាជាធរមាន មន្ត្រីអធិការកិច្ចត្រូវសហការជាមួយស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច កសាងនីតិវិធីអនុវត្តទៅតាមផ្លូវច្បាប់។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះ បណ្តាលបច្ចេកទេសវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមចំណុះក្រសួង និងទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**វង សុត**

***កន្លែងទទួល:***

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
*-ក្រសួងមហាផ្ទៃ*
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-គ្រប់សាលារាជធានី និងខេត្ត*
*" ដើម្បីជូនជ្រាប់*
*-ដូចប្រការ១៧ " ដើម្បីអនុវត្ត*
*-ឯកសារ-កាលប្បវត្តិ*